**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**

លេខ.៤៣.៧៦.....អពដ

L202101070010 | TD3110

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃ ក្នុងកម្មវិធី "GDT Taxpayer App"

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយស សូមជម្រាបជូនសាធារណជន ឬម្ចាស់អចលនទ្រព្យជាអ្នកជាប់ពន្ធដែលមានអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងក្រុងនៃខេត្តដែលជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យមេត្តាជ្រាបថា ក្នុងបរិបទនៃការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យពន្ធដារ ស្របតាមគោលនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍមុខងារ សម្រាប់បង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃក្នុងកម្មវិធី "GDT Taxpayer App" ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាព និងតម្លាភាពលើកិច្ចការគ្រប់គ្រងការប្រមូលចំណូល ក៏ដូចជាក្នុងន័យបង្កលក្ខណៈឱ្យកាន់តែងាយស្រួល និងឆាប់រហ័សជូនម្ចាស់អចលនទ្រព្យក្នុងការបង់ប្រាក់ពន្ធតាមទូរស័ព្ទដៃដោយផ្ទាល់ ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬតាមសាខាធនាគារពាណិជ្ជដែលជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារទៀតនោះឡើយ។ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាប និងណែនាំពីអត្ថប្រយោជន៍ និងរបៀបដំឡើងកម្មវិធីសម្រាប់បង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃដូចតទៅ÷

### I- អត្ថប្រយោជន៍នៃកម្មវិធីបង់ប្រាក់ពន្ធលើអចលនទ្រព្យលើទូរស័ព្ទដៃ

កម្មវិធីនេះនឹងបង្កលក្ខណៈងាយស្រួលដល់ម្ចាស់អចលនទ្រព្យជាអ្នកជាប់ពន្ធក្នុងការ÷

- ពិនិត្យមើលព័ត៌មានស្តីពីអចលនទ្រព្យដែលបានចុះបញ្ជី និងបានធ្វើបច្ចុប្បន្នភាពរួចរាល់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ
- បង់ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំរបស់ខ្លួន ដោយមិនចាំបាច់បំពេញព័ត៌មានក្នុងទម្រង់លិខិតប្រកាសពន្ធ
- ចំណេញពេលវេលា ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬសាខាធនាគារពាណិជ្ជជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ
- មិនចាំបាច់ទៅកាន់សាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យនោះស្ថិតនៅ ដើម្បីធ្វើការផ្ទៀងផ្ទាត់បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ
- ទទួលបាននូវសេចក្តីជូនដំណឹងផ្សេងៗដូចជា÷ កាលបរិច្ឆេទនៃការប្រកាសបង់ពន្ធ កាលបរិច្ឆេទនៃការផុតកំណត់ការបង់ប្រាក់ពន្ធ ការប្រកាសបង់ប្រាក់ពន្ធខ្វះក្នុងការិយបរិច្ឆេទជាប់ពន្ធណាមួយ និងសេចក្តីជូនដំណឹងផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រភេទពន្ធនេះ។

### II- របៀបដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ

ដើម្បីអាចប្រើប្រាស់កម្មវិធីបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃនេះ ម្ចាស់អចលនទ្រព្យអាចទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃផ្ទាល់ខ្លួនដូចខាងក្រោម÷

- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ Android÷*** សូមចូលទៅកាន់ "Play Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនេះនៅក្នុងទូរស័ព្ទដៃ
- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ iOS÷*** សូមចូលទៅកាន់ "App Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ។



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L202101070010 | TD3110

III- **អំពីរបៀបប្រើប្រាស់កម្មវិធី និងបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមទូរស័ព្ទដៃ**

បន្ទាប់ពីដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃរួចហើយ ម្ចាស់អចលនទ្រព្យត្រូវ÷

១. បង្កើតគណនីប្រើប្រាស់ (សម្រាប់អ្នកជាប់ពន្ធដែលមិនទាន់មានគណនីប្រើប្រាស់)។

២. បន្ទាប់ពីបង្កើតគណនីរួច ម្ចាស់អចលនទ្រព្យអាចប្រើប្រាស់លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន ឬសារអេឡិកត្រូនិក ឬលេខទូរស័ព្ទ ឬលេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (TID) និងពាក្យសម្ងាត់ ដើម្បីចូលប្រើប្រាស់កម្មវិធី។

៣. បញ្ចូលព័ត៌មានអចលនទ្រព្យរបស់ខ្លួន ដោយប្រើប្រាស់លេខអត្តសញ្ញាណកម្មអចលនទ្រព្យ ***(ឧទាហរណ៍÷ PIN002-00xxxx000)*** និងលេខទូរស័ព្ទរបស់ម្ចាស់អចលនទ្រព្យដែលបានចុះបញ្ជី ឬបច្ចុប្បន្នភាពព័ត៌មានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ។

៤. ម្ចាស់អចលនទ្រព្យអាចធ្វើការបង់ប្រាក់តាមអនឡាញ (e-Payment) តាមរយៈធនាគារពាណិជ្ជជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ។

៥. កម្មវិធីនឹងផ្ញើជូននូវវិក្កយបត្រទៅកាន់សារអេឡិកត្រូនិក ដែលបានផ្តល់ជូននៅពេលបង្កើតគណនីប្រើប្រាស់។

៦. ករណីដែលម្ចាស់អចលនទ្រព្យមានបញ្ហាក្នុងការប្រើប្រាស់កម្មវិធីនេះ ឬមានបញ្ហាក្នុងការបង់ប្រាក់ពន្ធ សូមទំនាក់ទំនងមកមជ្ឈមណ្ឌលពិគ្រោះយោបល់ (GDT Call Center) តាមរយៈលេខទូរស័ព្ទ ១២៧៧ ឬ Facebook Page ផ្លូវការ ឬកម្មវិធី GDT Live Chat ឬគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ។

**បញ្ជាក់÷**
- កម្មវិធីនេះអាចប្រើប្រាស់បានសម្រាប់តែអចលនទ្រព្យដែលបានចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានរួចរាល់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ តែប៉ុណ្ណោះ
- ចំពោះអចលនទ្រព្យទាំងឡាយណា ដែលមិនទាន់បានចុះបញ្ជី ឬមិនទាន់បានធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ ម្ចាស់អចលនទ្រព្យត្រូវអញ្ជើញមកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអចលនទ្រព្យនោះស្ថិតនៅ ដើម្បីចុះបញ្ជីបង់ពន្ធលើអចលនទ្រព្យ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ ឱ្យបានរួចរាល់ជាមុនសិន ទើបអាចចូលប្រើប្រាស់កម្មវិធីនេះបាន។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់ GDT Call Center នៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈលេខទូរស័ព្ទ ១២៧៧ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ៤:៤៥ នាទីរសៀល រៀងរាល់ថ្ងៃធ្វើការ។

អគ្គនាយកដ្ឋានពន្ធដារជឿជាក់យ៉ាងមុតមាំថា សាធារណជន ឬម្ចាស់អចលនទ្រព្យដែលជាអ្នកជាប់ពន្ធ នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីកម្មវិធីនេះ ជាពិសេសចំណេញពេលវេលា និងងាយស្រួលក្នុងការបង់ប្រាក់ពន្ធ ព្រមទាំង អាចតាមដានពីស្ថានភាពនៃការបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួន បានទាន់ពេលវេលាទៀតផងដែរ។

L202101070010 | TD3110

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យ តាមរយៈការបង់ប្រាក់ពន្ធលើអចលនទ្រព្យ តាមទូរស័ព្ទដៃ ឱ្យបានផុសផុល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមការគួរ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

*សូមស្កេនទីនេះដើម្បីទាញយកកម្មវិធីមកប្រើប្រាស់*

GET IT ON Google Play

Download on the App Store

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**